# យុថ្កានៃទីបន្ទាល់

ម៉ារី អ៊ិន ខុក
ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានយុវនារីទូទៅ

*ពង្រឹងទីបន្ទាល់របស់អ្នកដោយការធ្វើតាមគំរូនេះ នៃការអធិស្ឋាន និងការសិក្សា ហើយការគោរពតាមបទបញ្ញត្តិ ទាំងឡាយ ។*

នៅពេលខ្ញុំរស់នៅក្នុងតំបន់អាស៊ី ខ្ញុំបានឃើញមានត្រពាំងទឹកជាច្រើន ដែលដុះពេញទៅដោយផ្ការំចង់ដ៏ស្រស់ស្អាត និងរីកស្គុះស្គាយ ។ វាមានបន្ថែមនូវសម្រស់ស្ងៀមស្ងាត់ និងក្លិនពិដោរឈ្ងុយឈ្ងប់ បើគ្មានផ្ការំចង់នោះទេ វាគ្រាន់តែជាត្រពាំងមានពេញដោយទឹកផុកតែប៉ុណ្ណោះ ។ ស្លឹករំចង់អណ្ដែតលើផ្ទៃទឹក ដើមរំចង់ដុះវែង ចាក់ឫសជាយុថ្កាយ៉ាងមាំនៅក្នុងត្រពាំង ។ ដើមចេះតែដុះលូតលាស់ ដើម្បីឱ្យមានលំនឹងដល់ផ្កា ទោះបីជាពេលមានភ្លៀងធ្លាក់ជោគជាំ ហើយធ្វើឱ្យទឹកក្នុងត្រពាំងកើនឡើងប៉ុណ្ណាក៏ដោយ ។

បងប្អូនស្ត្រីវ័យក្មេងជាទីស្រឡាញ់របស់ខ្ញុំ អ្នកគឺដូចជាផ្កាដ៏ស្រស់ស្អាតនេះ ។ ភាពស្រស់ថ្លា ភាពបរិសុទ្ធ និងសម្រស់របស់អ្នក បន្ថែមនូវសេចក្ដីល្អដ៏ច្រើននៅក្នុងជីវិតរស់នៅរបស់យើង និងជីវិតរស់នៅរបស់គ្រួសារអ្នក ។ អ្នករស់នៅក្នុងពិភពលោកដ៏ឧបសគ្គមួយ ដែលបំពុលទៅដោយសេចក្ដីល្បួង និងការសាកល្បងយ៉ាងច្រើន ប៉ុន្តែទីបន្ទាល់របស់អ្នកអំពីព្រះយេស៊ូវគ្រីស្ទ អាចធ្វើជាយុថ្ការបស់អ្នក ។ សេចក្ដីជំនឿទៅលើព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទនឹងពង្រឹង ហើយជួយឱ្យទីបន្ទាល់របស់អ្នករីកចំរើន ហើយអ្នកនឹងអាចងើបឡើងខ្ពស់ពីសេចក្ដីអាក្រក់របស់លោកិយ ហើយរក្សាទីតាំង នៃសេចក្ដីសុចរិតរបស់អ្នក ។

យុថ្កាត្រូវបានឱ្យនិយមន័យថា "ជាអ្វីមួយដែលផ្ដល់លំនឹង ឬទំនុកចិត្តនៅក្នុងស្ថានភាពមិនជាក់លាក់" ។ 1 ទីបន្ទាល់របស់អ្នកនឹងធ្វើជាយុថ្ការបស់អ្នក ហើយនឹងផ្ដល់ដល់អ្នកនូវទំនុកចិត្តដើម្បីឈរ "ខ្ជាប់ខ្ជួន និងនឹងនរ" 2 នៅក្នុងការរក្សានូវបទបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់នៅក្នុងពិភពលោកដែលមិនពិតប្រាកដមួយ ។

ឥឡូវនេះ ទីបន្ទាល់របស់អ្នកកំពុងតែរីកចំរើនឡើង ដូចជាដើមរំចង់ ។ សេចក្ដីជំនឿរបស់អ្នកនឹងជួយឱ្យវារីកលូតលាស់ ហើយរក្សាវាឱ្យរឹងមាំ ទោះបីជាពេលអ្នកប្រឈមមុខនឹងឧបសគ្គ និងការល្បួងយ៉ាងច្រើននៃលោកិយ ដែលបានបំផុសជាមួយនឹងគ្រឿងញៀនទាំងឡាយ មតភាព រូបអាសអាភាស និងអំពើគ្មានសីលធម៌ ។

"សេចក្ដីជំនឿជាអំណោយទានមកពីព្រះ ប៉ុន្តែអ្នកត្រូវចិញ្ចឹមបីបាច់សេចក្ដីជំនឿរបស់អ្នកដើម្បីធ្វើឱ្យមានកាន់តែខ្លាំងឡើង... ។ អ្នកអាចចិញ្ចឹមបីបាច់ថែរក្សាអំណោយទាន នៃសេចក្ដីជំនឿរបស់អ្នក ដោយការអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ... ។ អ្នកកអាចពង្រឹងសេចក្ដីជំនឿរបស់អ្នកតាមរយៈការរក្សាបទបញ្ញត្តិ... ។ អ្នកក៏អាចអភិវឌ្ឍសេចក្ដីជំនឿរបស់អ្នកតាមរយៈការសិក្សាព្រះគម្ពីរ និងពាក្យសំដីរបស់ព្យាការី នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ" ។3

ខ្ញុំដឹងថា យុវនារីមួយចំនួនដែលមានសំណួរអំពីសំលៀកបំពាក់រម្យទម ។ ដើម្បីទទួលបានចម្លើយចំពោះសំណួរទាំងឡាយរបស់ពួកគេ ពួកគេបានធ្វើតាមគំរូនេះយ៉ាងជាក់លាក់: ពួកគេបានអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ ពួកគេបានសិក្សាបទគម្ពីរ និងពាក្យរបស់ព្យាការីថ្ងៃចុងក្រោយរបស់យើង ហើយពួកគេគោរពប្រណិបត្តិនៅក្នុងការរស់នៅតាម

បទដ្ឋាននៃភាពរម្យទម។ នៅពេលពួកគេទទួលបានចម្លើយចំពោះសំណួររបស់ពួកគេ សេចក្តីជំនឿរបស់ពួកគេបានកើនឡើង ហើយទីបន្ទាល់របស់ពួកគេត្រូវបានពង្រឹង។ ខ្ញុំនឹងអញ្ជើញឱ្យអ្នករាល់គ្នាម្នាក់ៗធ្វើតាមគំរូនេះ។

ទីមួយ អធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌របស់អ្នក។ សុំទ្រង់ឱ្យជួយនៅក្នុងការស្វែងរកចម្លើយចំពោះសំណួររបស់អ្នក។

ព្យាការីរបស់យើង ប្រធានថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍នៅក្នុងសន្និសីទសារព័ត៌មានដំបូងរបស់លោកថា:

"ពេលខ្លះ ចម្លើយដែលល្អបំផុត ដែលមនុស្សវ័យក្មេងអាច [ទទួល] ចំពោះសំណួរទាំងឡាយនៃជីវិត ត្រូវបានរកឃើញ នៅពេលលត់ជង្គង់របស់ពួកគេចុះ អំពាវនាវទៅកាន់ព្រះវរបិតាសួគ៌របស់យើង។

"បើពួកគេនឹងចងចាំថាព្រះអម្ចាស់យកចិត្តទុកដាក់អំពីពួកគេ ហើយនឹងឆ្លើយការអធិស្ឋានរបស់ពួកគេ នោះពួកគេនឹងអាចប្រឈមមុខគ្រប់ឧបសគ្គ ដែលមានមកចំពោះពួកគេ"។ 4 ការអធិស្ឋាននឹងពង្រឹងសេចក្តីជំនឿរបស់អ្នក ហើយជាយុថ្កានៃទីបន្ទាល់របស់អ្នក។

បន្ថែមពីលើការអធិស្ឋាន គឺការសិក្សាបទគម្ពីរអំពីសេចក្តីជំនឿ។ អាលម៉ា ជំពូកទី 32:27 គឺជាកន្លែងដ៏ល្អបំផុតមួយ ដើម្បីចាប់ផ្តើមដំណើរការការរៀនសូត្រ ដើម្បីបង្កើនសេចក្តីជំនឿរបស់អ្នក: "ប៉ុន្តែមើលចុះ បើសិនជាអ្នករាល់គ្នាចង់ភ្ញាក់ឡើង ហើយដាស់សមត្ថភាពទាំងឡាយរបស់ខ្លួន គឺដើម្បីធ្វើការពិសោធន៍ដល់ពាក្យសំដីរបស់ខ្ញុំ ហើយអនុវត្តសេចក្តីជំនឿមួយភាគតូច មែនហើយ គឺបើសិនជាអ្នករាល់គ្នាពុំអាចធ្វើអ្វីក៏ដោយក្រៅពីការចង់ជឿ នោះសូមឱ្យចំណង់នេះមាននៅ ក្នុងខ្លួនអ្នកគឺរហូតដល់អ្នកអាចទុកកន្លែងមួយ សំរាប់ពាក្យសំដីរបស់ខ្ញុំមួយភាគចុះ"។

តើអ្នកយល់ព្រមដើម្បីសាកល្បងការពិសោធន៍របស់អាលម៉ា ដើម្បីបង្កើនសេចក្តីជំនឿរបស់អ្នកឬទេ? តើអ្នកអាចអនុវត្តសេចក្តីជំនឿតែមួយភាគតូចបានទេ? តើអ្នកមានចំណង់ជឿដែរឬទេ?

នៅពេលអ្នករៀនមកពីបទគម្ពីរ ខ្ញុំដឹងថាព្រះអម្ចាស់នឹងប្រទានពរដល់អ្នក ជាមួយនឹងព្រះវិញ្ញាណរបស់ទ្រង់ ហើយដូចជាយុវនារីដែលយើងបានស្តាប់នៅយប់នេះ ការយល់ដឹងរបស់អ្នកនឹងត្រូវបានបំភ្លឺ។ បទគម្ពីរនឹងបង្កើនសេចក្តីជំនឿរបស់អ្នក ហើយនឹងជួយជាយុថ្កាទីបន្ទាល់របស់អ្នក។

ការសិក្សាពាក្យសំដីរបស់ពួកព្យាការីនៅថ្ងៃចុងក្រោយរបស់យើង ក៏នឹងបង្កើនសេចក្តីជំនឿរបស់អ្នកផងដែរ។ "អ្នកអាចទុកចិត្តជានិច្ចកាលចំពោះព្យាការីដែលនៅរស់។ ការបង្រៀនរបស់ពួកលោក ឆ្លុះបញ្ចាំងពីព្រះហឫទ័យ នៃព្រះអម្ចាស់" 5 ហើយនឹងជួយជាយុថ្កាទីបន្ទាល់របស់អ្នក។

ប្រធាន ស្ពែនស៊ើរ ដបុលយូ ឃីមបឹល ជាព្យាការីម្នាក់នៃពួកព្យាការីនៅថ្ងៃចុងក្រោយរបស់យើង បានផ្តល់ប្រឹក្សាដល់យុវវ័យឱ្យរក្សាស្តេកខ្លួនឱ្យរឹងមាំ ដើម្បីជួយពួកគេឱ្យ "ខ្ជាប់ខ្ជួន និងនឹងនរ" នៅពេលលោកបាន បង្រៀនថា: "មនុស្សវ័យក្មេងរបស់យើង គួរតែរក្សាស្តេកខ្លួនឱ្យរឹងមាំតាំងពីក្មេង...។ ស្តេកមានពីរប្រភេទគឺ: 'រឿងនេះ ខ្ញុំ *នឹងធ្វើវា* ហើយ 'រឿងនេះខ្ញុំ *មិនធ្វើវា ...។* តាំងពីក្មេង យុវវ័យគួរតែបានរស់នៅតាមផែនការមួយ...។ នៅពេលដែលផ្លូវមួយដូច្នេះត្រូវបានកំណត់ឡើង ហើយគោលដៅត្រូវបានដាក់ឡើង វានឹងងាយស្រួលជាងដើម្បីតទល់នឹងការល្បួងជាច្រើន ហើយនិយាយនៅលើកទីមួយថា 'ទេ' ចំពោះបារី និយាយនៅលើកទីមួយថា 'ទេ' ចំពោះគ្រឿងស្រវឹង... និយាយនៅលើកទីមួយថា 'ទេ' ចំពោះមធ្យោបាយដែលមិនត្រឹមត្រូវ ដែលនាំបន្តិចម្តងៗទៅកាន់ការអនុវត្តរឿងអសីលធម៌"។6

យើងមានឧបករណ៍ដ៏ពិសេស ដើម្បីជួយយើងឱ្យរក្សាស្តេកខ្លួនឱ្យរឹងមាំ។ វាគឺជាកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន។* នៅក្នុងកូនសៀវភៅនេះ អ្នកនឹងរកឃើញនូវពាក្យរបស់ពួកព្យាការីនៅថ្ងៃចុងក្រោយរបស់យើង។ "ស្តេក" ដែលប្រធាន ឃីមបឹល បានពិពណ៌នាគឺមាននៅក្នុងសៀវភៅនេះ: "ខ្ញុំ *នឹងធ្វើ*" និងរឿងដែ "ខ្ញុំ *នឹងមិនធ្វើ*"។

ទោះជាយ៉ាងណាក៏ដោយ វាមិនទាន់គ្រប់គ្រាន់ទេ ដែលគ្រាន់តែអានពាក្យសំដីរបស់ពួកព្យាការី។ អ្នកត្រូវតែធ្វើតាមជំហានចុងក្រោយនៅក្នុងគំរូរបស់យើង ហើយ "រក្សាបទដ្ឋានទាំងនេះ និងរស់នៅតាមសេចក្តីពិតទាំងឡាយនៅក្នុងបទគម្ពីរ"។ 7 នេះគឺជាផ្នែកដែលពិបាក ប៉ុន្តែតាមការរៀបចំទុកជាមុន នូវអ្វីដែលអ្នកនឹងធ្វើ និងអ្វីដែលអ្នកនឹងមិនធ្វើ នោះការរស់នៅតាមផែនការនោះ អ្នកអាចធ្វើបាន!

សេចក្តីជំនឿគឺជាគោលការណ៍មួយនៃសកម្មភាព។ ខ្ញុំសូមប្រាប់អ្នកអំពីយុវនារីមួយចំនួន ដែលបានសិក្សាពាក្យសំដីរបស់ពួកព្យាការីនៅក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* រួចហើយធ្វើសកម្មភាព។ ពួកគេបានបង្កើតផែនការមួយ បានសម្រេចចិត្តនូវអ្វីដែលពួកគេនឹងធ្វើ និងអ្វីដែលពួកគេនឹងមិនធ្វើ រួចហើយបានរស់នៅតាមផែនការនោះ។

ការណែនាំមួយនៅក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* បានថ្លែងថា: "តាមរយៈសំលៀកបំពាក់ និងរូបរាងរបស់អ្នក អ្នកអាចបង្ហាញព្រះអម្ចាស់ថា អ្នកដឹងថារូបកាយរបស់អ្នកមានតម្លៃប៉ុណ្ណា។ អ្នកអាចបង្ហាញថាអ្នកគឺជាសិស្សម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ"។8

បន្ទាប់ពីបានសិក្សាពាក្យសំដីទាំងនេះ យុវនារីម្នាក់នៅក្នុងថ្នាក់ ដែលអ្នកឃើញនៅយប់នេះបានដឹងថា ប្រហែលជាសំលៀកបំពាក់មួយចំនួនរបស់នាង មិនទាន់មានភាពសមរម្យទាំងស្រុងទេ។ តាមរយៈការអធិស្ឋាន និងការសិក្សាបទគម្ពីរ នាងត្រូវបានរំលឹកថា នាងគឺជាសិស្សម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ ហើយថានៅក្នុងនាមជាអ្នកតំណាងឱ្យទ្រង់ នាងចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរខ្លះៗ។ នាងមិនចង់មានអ្វីមួយនៅក្នុងសំលៀកបំពាក់របស់នាងគឺជាការល្បួងទេ ដូច្នេះនាងបានពិនិត្យមើលក្នុងទូសំលៀកបំពាក់របស់នាង និងថតទូរ ហើយបានបោះចោលនូវអ្វីដែលមិនសមរម្យ។ នាងបាននិយាយថា "ខ្ញុំនឹងជាមនុស្សឆ្លាត បើខ្ញុំមិនលសំលៀកបំពាក់ដែលនៅក្នុងហាង ដែលខ្ញុំដឹងថាខ្ញុំមិនគួរពាក់វា នោះ។ ហេតុអ្វីត្រូវឱ្យមានការល្បួង?" ដំណោះស្រាយដ៏រឹងមាំនោះ បានបង្ហាញដល់ព្រះអម្ចាស់ថា នាងគោរពដល់រូបកាយរបស់នាងហើយនាងបានរក្សាស្ដីងយ៉ាងរឹងមាំនៅក្នុងភាពសមរម្យ។

យុវនារីម្នាក់ទៀតនៅក្នុងថ្នាក់ បានទទួលស្គាល់ថា ការសម្រេចចិត្តរបស់នាងនៅក្នុងការស្លៀកពាក់គឺមានឥទ្ធិពលដល់របៀបដែលប្អូនស្រីតូចរបស់នាងស្លៀកពាក់ដែរ។ នៅត្រង់បន្ទាត់មួយក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* បានថ្លែងថា: "ការស្លៀកពាក់របស់អ្នកបង្ហាញថា អ្នកជានរណា។ ការស្លៀកពាក់របស់អ្នកបង្ហាញសារដំណឹងអំពីអ្នក ហើយវាមានឥទ្ធិពលនូវរបៀបដែលអ្នកនឹងអ្នកដទៃធ្វើអំពើ"។ 9 នាងបានសម្រេចចិត្តធ្វើការផ្លាស់ប្តូរខ្លះៗនៅក្នុងការស្លៀកពាក់របស់នាង ដោយដឹងថានាងមានការទទួលខុសត្រូវមួយ ដើម្បីធ្វើជាគំរូល្អចំពោះប្អូនស្រីនាង។ នាងបានបោះស្តីងកាន់តែរឹងមាំ និងមានឥទ្ធិពលដល់ជំរើសការស្លៀកពាក់របស់ប្អូននាង។

បទដ្ឋាននៃ "ការកំសាន្ត និងប្រព័ន្ធផ្សព្វផ្សាយ" បង្រៀនយើងដើម្បី "ជ្រើសរើសតែការកំសាន្តឬប្រព័ន្ធផ្សព្វផ្សាយណា ដែលលើកទឹកចិត្តអ្នកបានហើយ។ ការកំសាន្តដែលល្អនឹងជួយឱ្យអ្នករាល់គ្នាមានគំនិតល្អ ហើយធ្វើការជ្រើសរើសដែលសុចរិត"។ 10 ខ្ញុំស្គាល់យុវនារីម្នាក់ និងប្អូនស្រីរបស់នាង ដែលស្តាប់ ស៊ី. ឌី. នៅពេលពួកគេដឹងថាពាក្យក្នុងនោះមិនលើកដំកើង ហើយមិនជួយឱ្យពួកគេមានគំនិតល្អ។ ពួកគេទាំងពីរនាក់មើលគ្នាទៅវិញទៅមក ហើយបានដឹងតាម

រយៈព្រះវិញ្ញាណ ថាពួកគេមិនគួរស្តាប់តន្ត្រីប្រភេទនេះទេ។ បងស្រីបានយកញញួរ ហើយពួកគេទាំងពីរបានយក ស៊ី.ឌី. ដំកំទេចចោល។ តាំងពីក្មេង ពួកគេបានបោះស្មឹងយ៉ាងរឹងមាំចំពោះតន្ត្រី។ ពួកគេបានដឹងនូវអ្វីដែលពួកគេនឹងស្តាប់ និងមិនគួរស្តាប់ ហើយអាចរស់នៅក្នុងផែនការរបស់ពួកគេ ដោយការធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាណ។ ទង្វើតូចនេះបានពង្រឹងដល់ពួកគេ ហើយផ្តល់ទំនុកចិត្តឱ្យពួកគេដើម្បីគោរពតាម ពេលស្ថិតនៅក្នុងស្ថានភាពកាន់តែពិបាកជាងនេះ។

យុវនារីម្នាក់ទៀត បានសម្រេចចិត្តថាស្មឹងមួយរបស់នាងក្នុងចំណោមស្មឹងជាច្រើននៅក្នុងជីវិតរបស់នាង គឺដើម្បីរក្សាថ្ងៃឈប់សំរាក មិនថាស្ថានភាពរបស់នាងយ៉ាងណានោះទេ។ រយៈពេលឆ្នាំមួយនោះ បន្ទាប់ពីបានទទួលបុណ្យជ្រមុជទឹកក្លាយជាសមាជិកនៃសាសនាចក្រ ជាមួយនឹងគ្រួសាររបស់នាង វួដរបស់នាងត្រូវបានបំបែក។ គ្រួសាររបស់នាងត្រូវបានចាត់ឱ្យទៅវួដថ្មីដែលបំបែកចេញ ហើយនាងគឺជាយុវនារីតែម្នាក់ឯងគត់ ដែលត្រូវបានសុំឱ្យចូលរួមនៅក្នុងវួដថ្មី។ ឪពុកម្តាយរបស់នាងជំទាស់នឹងការផ្លាស់ប្តូរ ហើយឈប់ចូលរួមនឹងសាសនាចក្រ ប៉ុន្តែនាងចង់ធ្វើតាមការណែនាំនៅក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ត្រង់ "រក្សាថ្ងៃឈប់សំរាក"។ នាងបានសម្រេចចិត្តថាចូលរួមនៅក្នុងវួដថ្មី ពេលណាដែលគាត់អាច។ នាងបានដាស់ប្អូនស្រីពីដំណេក រៀបចំអាហារពេលព្រឹកដាក់នំសីរៀលពីរចាន ហើយពួកគេទាំងពីរនាក់បានចូលរួមពេញម៉ោងការប្រជុំ។

នៅថ្ងៃអាទិត្យ នាងអានព្រះគម្ពីររបស់នាង ហើយអនុវត្តតាមការពង្រីកខ្លួនរបស់ក្រុមយុវនារី។ ការសម្រេចចិត្តរបស់នាងដើម្បី "ខ្ជាប់ខ្ជួន និងនឹងនរ" នៅក្នុងការរក្សាថ្ងៃឈប់សំរាក បានលើកទឹកចិត្តឱ្យម្តាយរបស់នាងឱ្យចាប់ផ្តើមចូលរួមនៅក្នុងសាសនាចក្រម្តងទៀត។ ម្តាយរបស់នាងបានថ្លែងទីបន្ទាល់ថា គំរូនៃភាពខ្ជាប់ខ្ជួនកូនស្រីរបស់គាត់នៅក្នុងការរស់នៅតាមដំណឹងល្អ និងការមើលឃើញសេចក្តីល្អរបស់នាង បានជួយឱ្យគាត់ត្រឡប់មកចូលរួមសកម្មភាពវិញ។

"អ្នកបង្ហាញពីសេចក្តីជំនឿរបស់អ្នកតាមរយៈសកម្មភាព--- តាមរបៀបដែលអ្នករស់នៅ"។ 11 ជីវិតរបស់យុវនារីទាំងនេះ បានបង្ហាញអំពីសេចក្តីជំនឿរបស់ពួកគេ។ ហើយកំណត់ចំណាំថា សេចក្តីជំនឿរបស់ពួកគេ និងគំរូនៃការរស់នៅចេញលទ្ធផលជា "ការងារល្អ"។ បងប្អូនស្រីប្រទានពរដល់បងប្អូនស្រី ហើយកូនស្រីម្នាក់បានជួយម្តាយរបស់នាងឱ្យត្រឡប់មកកាន់សកម្មភាពសាសនាចក្រវិញ។

អ្នករាល់គ្នាមួយចំនួនអាចមានអារម្មណ៍ថា អ្នកមិនអាចងើបចេញពីភក់ដែលបំពុលនោះបានទេ ថាស្ថានភាពរបស់អ្នកពិបាកពេក ការសាកល្បងរបស់អ្នកខ្លាំងពេក ការល្បួងរបស់អ្នកធំពេក។ ប៉ុន្តែសូមចងចាំការសន្យារបស់អាលម៉ា: "នរណាដែលដាក់ទីទុកចិត្តរបស់ខ្លួនទៅលើព្រះ អ្នកនោះហើយដែលនឹងបានគាំទ្រនៅក្នុងការពិសោធន៍របស់គេ និងវិបត្តិរបស់គេ និងការទុក្ខវេទនារបស់គេ ហើយនឹងត្រូវបានលើកឡើងនៅថ្ងៃចុងក្រោយបង្អស់"។ 12 មានចាំទេ ដើមរំចង់បានដុះឡើងនៅក្នុងភាពលំបាក ហើយដូចជាដើមរំចង់លើកផ្ការំចង់ឡើង សេចក្តីជំនឿរបស់អ្នកនឹងគាំទ្រ និងលើកអ្នកឡើង។

បងប្អូនស្ត្រីវ័យក្មេងជាទីស្រឡាញ់របស់ខ្ញុំ ទីបន្ទាល់របស់អ្នកអំពីព្រះយេស៊ូវគ្រីស្ទគឺជាយុថ្ការរបស់អ្នក។ ចូរពង្រឹងសេចក្តីជំនឿរបស់អ្នកដោយការធ្វើតាមគំរូនៃការអធិស្ឋាន ការសិក្សា និងការគោរពប្រណិបត្តិចំពោះបទបញ្ញត្តិទាំងឡាយនេះ។ ចូរបោះស្មឹងឱ្យរឹងមាំ ដោយការសម្រេចចិត្តក្នុងពេលឥឡូវនេះនូវអ្វីដែលអ្នកនឹងធ្វើ និងអ្វីដែលអ្នកនឹងមិនធ្វើ រួចហើយធ្វើសកម្មភាពស្របទៅតាមផែនការរបស់អ្នក។

ខ្ញុំថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់ស្រឡាញ់អ្នករាល់គ្នាម្នាក់ៗ ហើយនឹងប្រទានពរដល់អ្នកនៅក្នុងកិច្ចខិតខំរបស់អ្នក ដើម្បី "ខ្ជាប់ខ្ជួន និងនឹងនរ" ។ 13 ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទពិត ហើយចំណេះដឹង និងទីបន្ទាល់របស់អ្នកអំពី ព្រះយេស៊ូវគ្រីស្ទ នឹងរក្សាអ្នកដោយយុថ្កាយ៉ាងល្អ ហើយអ្នកនឹងអាចរក្សាទីតាំង នៃសេចក្ដីសុចរិតរបស់អ្នក។ ការណ៍នេះ ខ្ញុំថ្លែងទីបន្ទាល់ដោយរាបទាប នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. Apple Computer Inc. Dictionary Version 1.0.1 "យុថ្កា" ។

2. ម៉ូសាយ 5:15 ។

3. *ពិតចំពោះសេចក្ដីជំនឿៈ សេចក្ដីយោងនៃដំណឹងល្អ* (2004), ទំព័រ 55 ។

4. “16th President Fields Questions from Media” *Church News* ថ្ងៃទី 9 ខែកុម្ភៈ ឆ្នាំ 2008, 15 ។

5. *ពិតចំពោះសេចក្ដីជំនឿ* ទំព័រ 129 ។

6. *Miracle of Forgiveness* (1969), 236 ។

7. *ដើម្បីកម្លាំងនៃយុវជន* ទំព័រ 2 ។

8. *ដើម្បីកម្លាំងនៃយុវជន* ទំព័រ 14 ។

9. *ដើម្បីកម្លាំងនៃយុវជន* ទំព័រ 15 ។

10. *ពិតចំពោះសេចក្ដីជំនឿ* ទំព័រ 17 ។

11. *ពិតចំពោះសេចក្ដីជំនឿ* ទំព័រ 54 ។

12. អាលម៉ា 36:3 ។